00833002

002/19-09-2007-ECCC/TC
E1/96

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 08 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ពុធ ទី ២៥ ខែ កក្កដា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៨៤

រៀបចំដោយ: សែ កុលវុឌ្ឍី និង Andrew James MCINTYRE

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Andrew James MCINTYRE, លោក ឌុច ផារី, លោកស្រី Natacha Wexels-Riser |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, កញ្ញា សុង ឆវ័ន្ត, លោក សេង ប៊ុនឃាង, លោក Tarik ABDULHAK, លោក Salim NAKHJAVANI, លោក Dale Lysak |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ជេត វណ្ណលី |
| សាក្សី/អ្នកជំនាញ៖ លោក David CHANDLER (TCE-11) , លោក រួចឹម តុន ហៅរីជៀម ហៅភីភួន (TCW-564) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Simon MEISENBERG, កញ្ញា Julia LEMETAYER, លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សាសាក្សី TCW-564) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.២៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ១០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០៤<br>១១.២៥ | ០៩.០៧<br>១១.២៥ |
| ការបន្តតាំងសំណួរទៅសាក្សីជំនាញ David Chandler (TCE-11) | មេធាវីការពារក្តី ខៀវ សំផន | ០៩.០៧ | ១១.២១ |
| សេចក្តីសម្រេចទាក់ទងនឹងការជំទាស់របស់មេធាវីការពារក្តី អៀង សារី ពីភាពមិនស៊ីសង្វាក់គ្នារវាងប្រតិចារិកបទសម្ភាសន៍របស់សាក្សីរួចឹម តុន និងកំណត់ហេតុស្តាប់ចម្លើយសាក្សី | អង្គជំនុំជម្រះ | ១៣.៣០ | ១៣.៥២ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅសាក្សី រូចឹម តុន (TCW-564) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៣.៥២<br>១៤.១៣ | ១៤.១៣<br>១៦.០០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី (៩.០៤) និង នួន ជា (១១.២៥) តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ (អៀង សារី សម្រាប់រយៈពេលពេញមួយថ្ងៃ និង នួនជា សម្រាប់សវនាការពេលរសៀល)។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំ។

**ការបន្តតាំងសំណួរទៅសាក្សីជំនាញ** David Chandler (TCE-11)

មេធាវីការពារក្តីឱ្យ ខៀវ សំផន បានបន្ត និងបញ្ចប់ការតាំងសំណួររបស់ខ្លួនទៅសាក្សីជំនាញ David Chandler (TCE-11)។

**ការតាំងសំណួរទៅសាក្សី រូចឹម តុន ហៅ គី តួន ហៅ ទី ចៀម** (TCW-564)

ប្រធានអង្គជំនុំជម្រះបានសួរសំណួរបឋមមួយចំនួនទៅសាក្សី ទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី ព្រមទាំងប្រាប់អំពីសិទ្ធិនឹងករណីកិច្ចរបស់សាក្សី។ បន្ទាប់មកសហព្រះរាជអាជ្ញា បានចាប់ផ្តើមតាំងសំណួរទៅសាក្សី រូចឹម តុន។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្តីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/182 | 13.2 | 00019108-00019126<br>00183393-00183408<br>00292868-00292886 | ការប្រជុំអចិន្ត្រៃយ៍ថ្ងៃទី ៩ តុលា ៧៥<br>Permanent 's meeting of committee on 9 October 1975<br>La réunion du Comité Permanent du 9 octobre 1975 | P | | p. 2 | |
| E3/1683 | D108/50/1.75 | 00825418-00825422,<br>00823678-00823691,<br>00701668-00701679,<br>00820987-00820997<br>00193067-00193488<br>00824485-00824491,<br>00726657-00726663,<br>00825423-00825430 | [Partial T.] ឧបសម្ព័ន្ធ ៧៥៖ សៀវភៅមានចំណងជើងថា សោកនាដកម្មជាប្រវត្តសាស្ត្រនៃប្រទេសកម្ពុជា<br>Annex 75: Book entitled “The Tragedy of Cambodian History”<br>[Partial T.] Annexe 75: Livre de David P. Chandler “The Tragedy of Cambodian History, Politics, War and Revolution since 1945”- Extraits | P | | 00193250 | |
| E3/9 | D222/1.15 | 00755579-00755583<br>00396177-00396757<br>00639445-00640068 | [លិខិតបញ្ជាក់ការជំនួសឯកសារ]<br>[Partial T.] សៀវភៅនិពន្ធដោយ Philip Short មានចំណងជើងថា៖ "ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ"<br>[Surrogate Sheet] Book by Philip Short entitled "Pol Pot, The History of a Nightmare"<br>[Feuille remplacée] Livre écrit par Philip Short intituté "Pol Pot, Anatomie d'un cauchemar" | P | 00755581 | 00396199 | 00639458 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/17 | D222/1.3 | 00392897-00393174 | [Surrogate Sheet] CHANDLER David, Brother Number One | P | p. 60 | 00392974 | 00821724 |
| E3/63 | D107/3 | 00228843-00228846 00231408-00231412 00376053-00376057 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន<br>[Surrogate Sheet] Written Record of interview of PHY Phuon<br>[Feuille remplacée] Procès verbal d'audition de PHY Phuon | P | | | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (៩.០៧) និង នួន ជា (១១.២៥) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួននោះ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលរៀបចំឱ្យសាក្សីជំនាញត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ។
- បង្គាប់ឱ្យនាំសាក្សី រូចឹម តុន ទៅកាន់កន្លែងស្នាក់នៅ និងបង្គាប់អោយនាំគាត់ត្រឡប់មកសវនាការវិញឱ្យបានមុនម៉ោង០៩ ព្រឹក នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២។
- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងការជំទាស់របស់មេធាវីការពារក្តី អៀង សារី៖ មេធាវីការពារក្តី អៀង សារី បានជំទាស់ពីភាពមិនប្រក្រតីនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយផ្អែកលើការថតសម្លេងនៃកិច្ចសម្ភាសន៍នោះ។ អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះ ប្រសិនបើមានភាពមិនប្រក្រតីកើតឡើងក្នុងអំឡុងពេលនៃការតាំងសំណួរទៅសាក្សីរូបនេះ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២។ ដោយឡែកជនជាប់ចោទ អៀង សារី ឱ្យនាំខ្លួនមកកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ប្រសិនបើជនជាប់ចោទស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ។

| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
|---|
| សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលវុឌ្ឍី Andrew James MCINTYRE